ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# កំណត់ហេតុ

## កិច្ចប្រជុំតាមប្រព័ន្ធអនឡាញ
## ស្តីពី «ការមិនដាក់ទណ្ឌកម្មលើជនរងគ្រោះអំពើជួញដូរមនុស្ស»
## កាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១

ឆ្នាំពីរពាន់ម្ភៃមួយ ខែមិថុនា ថ្ងៃទីដប់ប្រាំមួយ នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានរៀបចំកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ (Zoom Meeting) ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សម្របសម្រួលដោយលោក ឈួន ណៃ ប្រធានអង្គការអាស៊ានអាក់(ASEAN-ACT)។ សមាសភាពចូលរួមប្រជុំសរុប ចំនួន៣៥នាក់ រួមមាន៖

1. លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ
2. លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ
3. ឯកឧត្តម ឧត្តមសេនីយ៍ឯក យ៉ែម ច័ន្ទណារ៉ុម អគ្គលេខាធិការរង គ.ជ.ប.ជ
4. ឯកឧត្តម ឧត្តមសេនីយ៍ឯក លី តុងហ៊ុយ អគ្គលេខាធិការរង គ.ជ.ប.ជ
5. លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ
6. ឯកឧត្តម ឧត្តមសេនីយ៍ត្រី តែ សុថារ៉េត អគ្គលេខាធិការរង គ.ជ.ប.ជ
7. លោកឧត្តមសេនីយ៍ទោ ហាង ជីវ័ន្ត ប្រធានលេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
8. លោកឧត្តមសេនីយ៍ទោ កែវ ផល្លា ប្រធានក្រុមជំនួយកិច្ចការយុត្តិធម៌ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
9. ឯកឧត្តម ហ៊ូ វុឌ្ឍី រដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
10. ឯកឧតត្តម ប៉ែន ពេជ្រសាលី អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ ក្រសួងយុត្តិធម៌
11. លោកស្រី សុខ សុមាលីដា ប្រធាននាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ នៃក្រសួងយុត្តិធម៌
12. ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ
13. ឯកឧត្តម ឧត្តមសេនីយ៍ឯក អ៊ុក ហៃសិឡា អគ្គនាយករង ទទួលបន្ទុកនីតិកម្ម នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍
14. លោកស្រី ព្រំ សុខន ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
15. លោក ពុធ បូរី ប្រធាននាយកដ្ឋាន នៃក្រសួងកិច្ចការនារី
16. លោក យស សុខេមរិន អនុប្រធាននាយកដ្ឋានកិច្ចការកុងស៊ុល នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

17. លោក ឈួន ណៃ ប្រធានអង្គការអាស៊ានអាក់ ( ASEAN-ACT )
18. លោកស្រី ម៉ារីកា ម៉ាក់កាដាំ ( Marika McAdam ) អង្គការអាស៊ានអាក់ ( ASEAN-ACT )
19. សមាជិក-សមាជិកា ផ្សេងៗទៀត នៃក្រសួង ស្ថាប័ន ពាក់ព័ន្ធ

ជាកិច្ចចាប់ផ្តើម លោក ឈួន ណៃ ជាមន្ត្រីសម្របសម្រួល នៃអង្គការអាស៊ានអាក់ បានមានមតិស្វាគមន៍ បើកកម្មវិធី និងបានលើកឡើងអំពីរបៀបវារៈនៃកិច្ចប្រជុំ ដែលបានផ្តោតសំខាន់ទៅលើប្រធានបទស្តីពី «គោលការណ៍មិនដាក់ទណ្ឌកម្ម លើជនរងគ្រោះដោយអំពើជួញដូរមនុស្ស» ដោយអង្គការ អាស៊ានអាក់ បានរៀបចំជាកម្រងសំណួរចំនួន២០ ចែកចេញជា៤ផ្នែក។ នៅមុនពេលចាប់ផ្តើមការឆ្លើយតបទៅនឹងសំណួរលោក ឈួន ណៃ ក៏បានអញ្ជើញលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ក៏ដូចជាឯកឧត្តម លោកជំទាវ តំណាងក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ដែលមានវត្តមានក្នុងកិច្ចប្រជុំ ធ្វើការណែនាំសមាសភាព។ បន្ទាប់ពីការណែនាំសមាសភាពបានបញ្ចប់លោក ឈួន ណៃ ក៏បានចាប់ផ្តើមកម្មវិធីសំណួរ-ចម្លើយដែលមានដូចតទៅៈ

<u>ផ្នែកទី១ «សំណួរទូទៅ»៖ គោលការណ៍មិនដាក់ទណ្ឌកម្មចែងថា ជនដែលត្រូវគេជួញដូរមិនគប្បីត្រូវគេដាក់ទណ្ឌកម្ម ឬទោសបញ្ញត្តិ សម្រាប់បទល្មើសដែលជននោះបានប្រព្រឹត្តដែលគឺជាផលលំបាកផ្ទាល់នៃប្រការដែលត្រូវបានគេជួញដូរ ឬដែលជនជួញដូរបានបង្ខំឱ្យធ្វើ។</u>

*សំណួរទី១៖ តើលោក-អ្នកយល់ថា គោលការណ៍នេះត្រូវបានគេយល់បានល្អ និងត្រូវបានអនុវត្តនៅកម្ពុជា ឬទេ ?*

ឆ្លើយតបទៅនឹងសំណួរទី១ លោកជំទាវ ជូ ប៊ុនអេង អនុប្រធានចិន្ត្រៃយ៍ គ.ជ.ប.ជ បានលើកឡើងថា កម្ពុជា ជាប្រទេសហត្ថលេខី នៃអនុសញ្ញា និងកតិកាសញ្ញា ពិភពលោក ស្តីពីសិទ្ធិមនុស្ស សិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិស្ត្រី សិទ្ធិកុមារ ។ល។ ក៏ដូចជាអនុសញ្ញាអាស៊ានប្រឆាំងនឹងការជួញដូរមនុស្សជាពិសេស ស្ត្រីនិងកុមារ ហើយយើងក៏មានច្បាប់ជាតិរបស់ខ្លួនគឺ រដ្ឋធម្មនុញ្ញ ដែលយើងបានចែងរួចហើយដើម្បីឆ្លើយតបទៅនឹង អនុសញ្ញា និងកតិកាសញ្ញាខាងលើ ហើយកម្ពុជាបាននឹងកំពុងតែអនុវត្ត ក្នុងការការពារ និងជួយដល់ជនរងគ្រោះ។ បន្ថែមលើនេះ ឯកឧត្តម ហ៊ូ វុឌ្ឍី រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏បានលើកឡើងថា ពាក់ព័ន្ធទៅនឹងលំហូរពលករ យើងមានពលករក្នុងស្រុកដែលពួកគាត់ទៅធ្វើការនៅទីក្រុង ឬនៅតំបន់សេដ្ឋកិច្ចពិសេស ឬចេញទៅធ្វើការនៅប្រទេសក្រៅ ដែលភាគច្រើនគឺទៅប្រទេសថៃ។ មួយទៀតគឺពលករបរទេស ដែលមកធ្វើការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្នុងច្បាប់ការងារ ក្នុងអាណត្តិនៃការអនុវត្តរបស់ក្រសួងការងារ រាល់បទល្មើសទាំងឡាយដែលកើតឡើង រវាងនិយោជក និងនិយោជិក ភាគច្រើនអាជ្ញាធរមានសមត្ថកិច្ចមិនទាន់បានកំណត់ជាក់លាក់ថា ជាករណីជួញដូរមនុស្សនៅឡើយទេ ដូច្នេះរាល់ការដោះស្រាយ គឺយើងតែងតែទុកកម្មករថាជាជនរងគ្រោះ ហើយព្យាយាមដោះស្រាយក្រៅប្រព័ន្ធតុលាការ។ លោកជំទាវ ជូ ប៊ុនអេង ក៏បានបន្ថែមថា ជារួមយើងតែងតែដាក់ចេញនូវវិធីសាស្ត្រក្នុងការកំណត់រកអត្តសញ្ញាណ ដើម្បីជាមូលដ្ឋានក្នុងការជួយដល់ជនរងគ្រោះពិតប្រាកដ ហើយគោលការណ៍មិនដាក់ទណ្ឌលកម្មដល់ជនរងគ្រោះគឺត្រូវបានអនុវត្ត ហើយយើងថែមទាំងបានផ្តល់ជូនជនរងគ្រោះ នូវសេវាសង្គ្រោះមួយចំនួនដូចជាផ្តល់ជាសេវាការពារក្តី ជួយធ្វើជាដើមបណ្តឹងដល់ជនរងគ្រោះជាស្ត្រីនិងកុមារ ក៏ដូចជាជំនួយចាំបាច់មួយចំនួន

ដូចជាគ្រឿងឧបភោគបរិភោគ និងអនាម័យជាដើម ដែលទាំងអស់នេះគឺជាអ្វីដែលកម្ពុជាបានអនុលោមទៅតាម ច្បាប់ និងគោលការណ៍ របស់អន្តរជាតិ។

*សំណួរទី២៖ នៅក្នុងសមត្ថកិច្ចប្រឆាំងការជួញដូររបស់លោក-អ្នក តើលោក-អ្នកមានតួនាទីជាក់លាក់អ្វីក្នុងការលើកជ្រោង និងអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្មនៅកម្ពុជា ?*

ឆ្លើយតបទៅនឹងសំណួរទី២ ឯកឧត្តម ប៉ែន ពេជ្រសាលី នៃអគ្គនាយកដ្ឋានកិច្ចការអយ្យការនិងព្រហ្មទណ្ឌ ក្រសួងយុត្តិធម៌ បានលើកឡើងថា ក្រសួងស្ថាប័នជាតិ តែងយកចិត្តទុកដាក់ក្នុងការជួយជនរងគ្រោះ ប៉ុន្តែការកំណត់អត្តសញ្ញាណ និងការស្វែងរកភស្តុតាងដាក់បន្ទុក គឺត្រូវតែធ្វើឡើងតាំងពីដំណាក់កាលដំបូង ក្នុងដែនសមត្ថកិច្ចរបស់ ស្ថាប័នពាក់ព័ន្ធ ព្រោះនៅដំណាក់កាលតុលាការការវិនិច្ឆ័យទៅលើជនរងគ្រោះ គឺផ្អែកទៅលើភស្តុតាង ដូច្នេះនៅចុងបញ្ចប់ស្ថានភាពនៃជនរងគ្រោះអាចនឹងប្រែប្រួល អាស្រ័យលើភស្តុតាង ដែលជនរងគ្រោះអាចបញ្ជាក់បាននៅចំពោះមុខតុលាការ។ ដូច្នេះខ្ញុំយល់ថា ទាំងចៅក្រម ទាំងព្រះរាជអាជ្ញា គឺពួកគាត់បានយល់ជ្រួតជ្រាបអំពីតួនាទីរបស់ពួកគាត់ក្នុងការការពារជនរងគ្រោះហើយ ប៉ុន្តែសម្រាប់ជនរងគ្រោះ ពិតប្រាកដ ឬមិនពិតប្រាកដ គឺអាស្រ័យលើភស្តុតាងដែលគាត់បានផ្តល់ឱ្យ មានន័យថាដើម្បីជួយដល់ជនរងគ្រោះ មានតែខាងវិស័យពាក់ព័ន្ធទាំងអស់ រួមទាំងជនរងគ្រោះខ្លួនឯង ត្រូវហ៊ានផ្តល់ព័ត៌មានពិត និងភស្តុតាង។ លោកស្រី ព្រំ សាខន ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបន្ថែមថា ក្រសួង បានដាក់ចេញនូវគោលការណ៍ គោលនយោបាយ និងបទដ្ឋានគតិយុត្តជាច្រើន ដែលគាំទ្រ និងការពារសិទ្ធិ របស់ជនរងគ្រោះ ក្រសួងក៏បានផ្តល់នូវការគាំទ្រទាំងផ្នែកទន់ (ផ្តល់ប្រឹក្សា ព្យាបាលផ្លូវចិត្ត) និងផ្នែករឹង (ផ្តល់ជំនួយសម្ភារ) តាំងពីពេលចាប់ផ្តើមករណី រហូតដល់បញ្ចប់ករណី ហើយក៏នៅតែបន្ត តាមដាន ដើម្បីធានាថាជនរងគ្រោះត្រូវបានការពារទាំងផ្លូវចិត្តនិងផ្លូវកាយ។ ពាក់ព័ន្ធនឹងបញ្ហានេះ លោកជំទាវ ជូ ប៊ុនអេង ក៏បានបន្ថែមថា នៅពេលដែលជួបប្រទះនឹងស្ថានភាព ដែលយើងសង្ស័យថាជនណាម្នាក់គឺជាជនរងគ្រោះដោយអំពើជួញដូរ នាយកដ្ឋានប្រឆាំងការជួញដូរ តែងតែសហការជាមួយនឹងនាយកដ្ឋានអន្តោប្រវេសន៍ ដើម្បីជួយដល់ជនរងគ្រោះ។ យើងឃើញថា រាជរដ្ឋាភិបាលកម្ពុជា ពុំដែលធ្វើការឃុំខ្លួន ជនអន្តោប្រវេសន៍ជាពិសេសកុមារ បើទោះបីជាពួកគេបានល្មើសច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ក៏កន្លងមកយើងមានមាត្រា៩៩ នៃក្រមព្រហ្មទណ្ឌ យើងមានមាត្រា៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនជាដើម សម្រាប់អនុវត្តជាក់ស្តែងកន្លងមក សម្រាប់ជនអន្តោប្រវេសន៍ដែលបានល្មើសច្បាប់អន្តោប្រវេសន៍ ជាឪពុកម្តាយដែលមានកូនតូច គឺយើងតែងតែបានអនុញ្ញាតឱ្យម្តាយបាននៅមើលថែកូន ឬជួយសម្រួលនីតិវិធីក្នុងការបណ្តេញចេញឱ្យបានឆាប់ដើម្បីពួកគាត់បាននៅមើលថែកូន ជាដើម។

<u>ផ្នែកទី២ «ការដាក់ទណ្ឌកម្មជនរងគ្រោះ និងការយកជនរងគ្រោះមកកាត់ទោសក្នុងការប្រតិបត្តិជាក់ស្តែង»៖ ជនរងគ្រោះអាចប្រព្រឹត្តបទល្មើសក្នុងអំឡុងពេលត្រូវគេជួញដូរ។ បទល្មើសទាំងនោះអាចទាក់ទងនឹង ឯកសារឬអន្តោប្រវេសន៍ ដែលនៅក្នុងនោះ ជនរងគ្រោះត្រូវបានគេជួញដូរឆ្លងព្រំដែន។ ក្នុងដំណាក់កាលកេងប្រវ័ញ្ចនេះ ជនជួញដូរអាចប្រព្រឹត្តបទល្មើស ទាក់ទងនឹងការងារខុសច្បាប់ ជាពិសេសនៅទីណាដែលពេស្យាចារ គឺជាអំពើខុសច្បាប់។</u>

*សំណួរទី៣៖ តើលោកអ្នកមានដឹងអំពីស្ថានភាពណាដែលនៅក្នុងនោះ ជនដែលត្រូវគេជួញដូរ ឬជនដែលត្រូវសន្មតថាត្រូវបានគេជួញដូរ ដែលមិនបានកំណត់អត្តសញ្ញាណជាផ្លូវការ ថាជាជនរងគ្រោះដោយអំពើជួញដូរ ត្រូវបានគេយកមកកាត់ទោស សម្រាប់បទល្មើសខាងក្រោមដែរឬទេ? សូមរៀបរាប់។*

ឆ្លើយតបទៅនឹងសំណួរទី៣ ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានលើកឡើងថា កន្លងមកគឺពុំទាន់មានរកឃើញនូវករណីដូចបានលើកឡើងខាងលើនៅឡើយទេ គឺមានតែករណីដែល ជនរងគ្រោះដោយអំពើជួញដូរមនុស្ស បានប្រព្រឹត្តបទល្មើសផ្សេងទៀត ដោយចេតនារបស់ខ្លួនគាត់ ដូចជាជួញដូរគ្រឿងញៀនជាដើម។ ទាក់ទងនឹងសមត្ថកិច្ចប្រឆាំងការជួញដូរមនុស្ស យើងពុំដែលធ្វេសប្រហែសក្នុងការកំណត់ អត្តសញ្ញាណជនរងគ្រោះឡើយ។ បន្ថែមលើនេះ ឯកឧត្តម ប៉ែន ពេជ្រសាលី ក៏បានបញ្ជាក់ថា ជាក់ស្តែងបើជនណាម្នាក់ ជាជនរងគ្រោះក្នុងបទល្មើសមួយ ប៉ុន្តែជាជនល្មើសក្នុងបទល្មើសមួយផ្សេងទៀត ជននោះត្រូវតែទទួលទោសក្នុងបទល្មើសនោះ លើកលែងតែង សកម្មភាពល្មើសនោះស្ថិតនៅក្រោមការគៀបសង្កត់ ឬបង្ខិតបង្ខំ ដោយជនណាម្នាក់ទៀតដោយអំពើជួញដូរមនុស្ស នោះជននោះនៅតែជាជនរងគ្រោះ។ លោក ផន ពុធបូរី ប្រធាននាយកដ្ឋាន នៃក្រសួងកិច្ចការនារី បានបន្ថែមថាកន្លងមកមានជនរងគ្រោះជាជនបរទេសដែលត្រូវបានជួញដូរមកកម្ពុជា ដើម្បីជួញដូរផ្លូវភេទ ជាក់ស្តែងយើងអាចចោទប្រកាន់ពួកគាត់ក្នុងបទល្មើសអន្តោប្រវេសន៍ ប៉ុន្តែជាក់ស្តែងយើងពុំដែលបានអនុវត្តទេ ផ្ទុយទៅវិញយើងនៅតែចាត់ទុកពួកគេថាជាជនរងគ្រោះ ហើយថែមទាំងបានជួយសម្រួល ក្នុងការរៀបចំឯកសារដើម្បីបញ្ជូនត្រឡប់ទៅប្រទេសដើមវិញ។ លោកជំទាវ ជូ ប៊ុនអេង ក៏បានធ្វើការបូកសរុបក្នុងសំណួរទី៣នេះថា ជារួមទោះបីជា យើងមិនទាន់អាចកំណត់អត្តសញ្ញាណថា ជនណាម្នាក់ជាជនរងគ្រោះក្នុងអំពើជួញដូរមនុស្សក្តី ក៏រាជរដ្ឋាភិបាលកម្ពុជា តែងតែផ្តល់នូវសេវាជំនួយគាំទ្រដល់ជននោះជានិច្ច។

*សំណួរទី៤៖ តើឯកឧត្តម លោកជំទាវ លោក លោកស្រី មានដឹងពីស្ថានភាពណា ដែលនៅក្នុងនោះជនដែលត្រូវគេជួញដូរ ដែលត្រូវបានកំណត់អត្តសញ្ញាណជាផ្លូវការ ថាជាជនរងគ្រោះដោយអំពើជួញដូរត្រូវបានគេយកទៅកាត់ទោស សម្រាប់បទល្មើសដែលពួកគេបានប្រព្រឹត្ត នៅក្នុងអំឡុង ពេលដែលត្រូវបានគេជួញដូរឬទេ? តើបទល្មើសអ្វី?*

*សំណួរទី៥៖ តើឯកឧត្តម លោកជំទាវ លោក លោកស្រី មានឧទាហរណ៍អំពីជនរងគ្រោះដោយអំពើជួញដូរ ដែលប្រឈមមុខនឹងស្ថានភាពដូចជា៖ ការឃាត់ខ្លួន ការឃុំខ្លួននៅនឹងកន្លែងអនុវត្ត ការងារឬកន្លែងអន្តោប្រវេសន៍ ការឃុំខ្លួននៅក្នុងមណ្ឌលស្នាក់នៅឬកន្លែងថែទាំ ការនិរទេស ការវិលត្រឡប់ដោយបង្ខំ ការឱ្យបង់ថ្លៃអន្តោប្រវេសន៍ ការផាកពិន័យអន្តោប្រវេសន៍ ការមិនបន្តលិខិតអនុញ្ញាតឱ្យស្នាក់នៅឬធ្វើការ ការមិនផ្តល់សញ្ជាតិ ។ល។ នៅកម្ពុជាដែរឬទេ? តើជនរងគ្រោះទាំងនេះ ត្រូវបានកំណត់អត្តសញ្ញាណជាផ្លូវការ ឬមិនត្រូវបានកំណត់អត្តសញ្ញាណ? សូមរៀបរាប់ដោយសង្ខេប។*

ពាក់ព័ន្ធទៅនឹងសំណួរទី៤ និងទី៥ គឺត្រូវបានឆ្លើយតបរួចទៅហើយនៅខាងលើ។

*សំណួរទី៦៖ តើឯកឧត្តម លោកជំទាវ លោក លោកស្រី យល់ថា ជនដែលត្រូវបានគេជួញដូរមានប្រភេទដូចជា៖ ជនរងគ្រោះជាបុរស ជនរងគ្រោះជាស្ត្រី ជនរងគ្រោះជាអ្នកស្រឡាញ់ភេទដូចគ្នា ជនរងគ្រោះជាកុមារ ពលរដ្ឋរបស់ប្រទេស មិនមែនពលរដ្ឋ ពលរដ្ឋមិនមានឯកសារ ជនរងគ្រោះដោយការកេងប្រវ័ញ្ចផ្លូវភេទ ជនរងគ្រោះដោយការកេងប្រវ័ញ្ចមិនមែនផ្លូវភេទ ជាដើម រងហានិយភ័យដោយឡែកយ៉ាងដូចម្ដេច ចំពោះការត្រូវបានដាក់ទោសសម្រាប់បទល្មើសដែលពួកគេបានប្រព្រឹត្ត ដោយសារតែពួកគេត្រូវបានគេជួញដូរ ប្រសិនបើមាន?*

ឆ្លើយតបទៅនឹងសំណួរទី៦ លោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានគូសបញ្ជាក់ថា នៅក្នុងព្រះរាជាណាចក្រកម្ពុជា ករណីជនរងគ្រោះជាកុមារ ជាស្ត្រីឬស្ត្រីមានផ្ទៃពោះ ឬអ្នកដែលមានកុមារតូចជាប់ខ្លួន គឺយើងតែងតែយកចិត្តទុកដាក់ច្រើនជាទីបំផុត ហើយចំពោះស្ត្រីដែលរងការកេងប្រវ័ញ្ចផ្លូវភេទ ឬការកេងប្រវ័ញ្ចដទៃទៀត ឱ្យតែយើងបានកំណត់ថា ពួកគេជាជនរងគ្រោះ ឬសង្ស័យថារងគ្រោះគឺយើងបានផ្តល់កិច្ចគាំពារដោយមិនប្រកាន់ថាជននោះ ជាបុរស ស្ត្រី អ្នកស្រឡាញ់ភេទដូចគ្នាឬអ្នកកែភេទ មិនថាខ្មែរឬបរទេសនោះទេ ប៉ុន្តែមានតែជនរងគ្រោះជាជនជាតិខ្មែរនៅបរទេស ដែលចេញទៅរកការងារ តាមការអូសទាញ របស់ឈ្មួញឬថៅកែបរទេសទៅវិញទេ ដែលតែងតែរងគ្រោះ។ ពួកគាត់មួយចំនួនបានទទួលរងនូវការឃុំខ្លួន ឬការដាក់ទោសទណ្ឌ ដោយបទល្មើសផ្សេងៗ រហូតដល់មានករណីខ្លះ សូម្បីតែរដ្ឋាភិបាលកម្ពុជា ដែលជាអាណាព្យាបាល ក៏ពុំបានទទួលការពន្យល់ ឬជូនដំណឹងទេ រហូតទាល់តែ ជនរងគ្រោះជាពលរដ្ឋកម្ពុជាត្រូវបានដោះលែង និងបញ្ជូនត្រឡប់មកវិញ ឬបានបាត់ខ្លួន ដែលទាំងនេះគឺផ្ទុយពីកម្ពុជា តែងតែគោរពតាម ច្បាប់ គោលការណ៍ ជាតិ និងអន្តរជាតិក្នុងការការពារដល់ជនរងគ្រោះ មិនថាជាពលរដ្ឋកម្ពុជា មិនថាជនបរទេស។ បន្ថែមលើនេះ ឯកឧត្តម ប៉ែន ពេជ្រសាលី និងឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី បានលើកឡើងដូចគ្នាថា គ្រប់ករណីដែលយើងរកឃើញជនបរទេស ជាជនរងគ្រោះក្តី ជាជនល្មើសក្តី គឺយើងតែងតែជូនដំណឹងទៅស្ថានតំណាងប្រទេស គ្រប់មធ្យោបាយ។ ឯកឧត្តម ហ៊ួ វុឌ្ឍី បានសំណូមពរឱ្យមានការយកចិត្តទុកដាក់គិតគូរ ការការពារដល់ ពលករលើទូកនេសាទសមុទ្រ ព្រោះពួកគាត់តែងតែប្រឈមមុខខ្លាំងក្នុងការជួញដូរ និងកេងប្រវ័ញ្ច។

ផ្នែកទី៣ «ច្បាប់ទាក់ទិននឹងការមិនដាក់ទណ្ឌកម្ម»៖ អនុសញ្ញាអាស៊ានប្រឆាំងនឹការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ(២០១៥)ចែងថា «អនុលោមតាម ច្បាប់ គោលការណ៍ និងគោលនយោបាយជាតិ និងក្នុងករណីសមស្រប ភាគីនីមួយៗត្រូវចាត់ទុក ជនរងគ្រោះដោយសារការជួញដូរមនុស្ស ថាមិនពាក់ព័ន្ធនឹងការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ឬខាងរដ្ឋបាលឡើយ ចំពោះសកម្មភាពល្មើសច្បាប់ដែលពួកគេបានប្រព្រឹត្ត ប្រសិនបើសកម្មភាពទាំងនោះ ជាប់ទាក់ទងដោយផ្ទាល់ ទៅនឹងសកម្មភាពនៃការជួញដូរមនុស្ស» (មាត្រា១៤(៧))។ នៅកម្រិតជាតិ នៅកម្ពុជា មាត្រា ៤៤ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ (២០០៨) ហាមឃាត់ការដាក់ទណ្ឌកម្ម មនុស្សដែលមានអាយុក្រោម១៥ឆ្នាំ សម្រាប់បទល្មើសកំណត់មួយចំនួន រួមមាន ការរួមភេទជាមួយអនីតិជនក្រោមអាយុ១៥ឆ្នាំ (មាត្រា៤២) និងអំពើអាសប្រឆាំងនឹងអនីតិជនក្រោមអាយុ១៥ឆ្នាំ (មាត្រា៤៣)។ ប៉ុន្តែមិនមានបទបញ្ញត្តិ មិនដាក់ទណ្ឌកម្មផ្សេងទៀត ដើម្បីការពារជនរងគ្រោះ ផុតពីការកាត់ទោសសម្រាប់បទល្មើសដែលពួកគេ បានប្រព្រឹត្ត ដោយសារតែពួកគេត្រូវបានគេជួញដូរ។

*សំណួរទី៧៖ តើច្បាប់នេះ មានប្រយោជន៍ឬទេក្នុងការការពារជនដែលត្រូវគេជួញដូរ ឱ្យផុតពីការដាក់ទណ្ឌកម្ម? ហេតុអ្វី?*

ឆ្លើយតបទៅនឹងសំណួរទី៧ ឯកឧត្តម ប៉ែន ពេជ្រសាលី បានលើកឡើងថា ច្បាប់ ទាំងអស់ខាងលើគឺពិតជាមានប្រយោជន៍។

*សំណួរទី៨៖ តើច្បាប់នេះត្រូវបានអនុវត្តជាក់ស្តែងកម្រិតណា? តើឯកឧត្តម លោកជំទាវ លោក លោកស្រី អាចផ្តល់ជាឧទាហរណ៍ ពីកន្លែង និងរបៀបដែលច្បាប់នេះត្រូវបានអនុវត្ត? ក្នុងករណីជួញដូរប្រភេទណា? បទល្មើសអ្វី?*

*សំណួរទី៩៖ ដើម្បីអនុវត្តបទបញ្ញត្តិនេះ តើជនរងគ្រោះត្រូវគេជួញដូរ ចាំបាច់ត្រូវកំណត់អត្តសញ្ញាណថាជាជនរងគ្រោះដោយការជួញដូរ ជាផ្លូវការដែរឬទេ?*

ពាក់ព័ន្ធនឹងសំណួរទី៨ និងទី៩ គឺត្រូវបានឆ្លើយតបក្នុងសំណួរខាងលើរួចហើយ។

*សំណួរទី១០៖ តើបទបញ្ញត្តិនេះមានតួនាទីអ្វីខ្លះក្នុងដំណាក់កាលស៊ើបអង្កេត? តើឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលស៊ើបអង្កេត មានឆន្ទានុសិទ្ធិធ្វើការចោទប្រកាន់ដែរឬទេ?*

ឆ្លើយតបទៅនឹងសំណួរទី១០ ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី បានលើកឡើងថា ជាទូទៅ នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌ បានទទួលពាក្យបណ្តឹង ឬបានទទួលព័ត៌មាន គឺយើងបានបើកការស៊ើបអង្កេតជាបឋម បន្ទាប់ពីកំណត់បានតម្រុយ គឺយើងត្រូវស្នើសុំទៅព្រះរាជអាជ្ញា ដើម្បីមានចំណាត់ការបន្ត និងកសាងសំណុំរឿង បញ្ជូនទៅតុលាការ។ ឯកឧត្តម ប៉ែន ពេជ្រសាលី បានគូសបញ្ជាក់ថា នៅពេលដែលអយ្យការមានការសង្ស័យតាមរយៈសំណុំរឿងនិងភស្តុតាង គឺអយ្យការគាត់មានឆន្ទានុសិទ្ធិ ក្នុងការចោទប្រកាន់បាន។ នៅដំណាក់កាល ចៅក្រមស៊ើបសួរ គឺគាត់ក៏មានឆន្ទានុសិទ្ធិក្នុងការស៊ើបសួរ ដាក់បន្ទុក ឬដោះបន្ទុក។ ដូច្នេះ ទាំងព្រះរាជអាជ្ញា ទាំងចៅក្រមស៊ើបសួរ ទាំងចៅក្រមជម្រះ គឺមានឆន្ទានុសិទ្ធិ និងឯករាជ្យ។

*សំណួរទី១៣៖ ក្នុងការអនុវត្តបទបញ្ញត្តិនេះ តើការផ្សារភ្ជាប់រវាងបទល្មើសរបស់ជនដែលត្រូវបានគេជួញដូរ និងការជួញដូរជននោះ ត្រូវបានកំណត់យ៉ាងដូចម្តេច?*

ឆ្លើយតបទៅនឹងសំណួរទី១៣ លោកជំទាវ ជូ ប៊ុនអេង បានគូសបញ្ជាក់ថាជាក់ស្តែងគឺយើងបានលើក ឡើងរួចមកហើយ តុលាការ មានឆន្ទានុសិទ្ធិក្នុងការវិនិច្ឆ័យបានថា ជននោះជាជនរងគ្រោះ ឬជាជនល្មើស។

<u>ផ្នែកទី៤ «គោលការណ៍ណែនាំ គោលនយោបាយ និងកិច្ចព្រមព្រៀង»៖ មានគោលការណ៍ ណែនាំថ្នាក់តំបន់មួយចំនួនដែលមានលក្ខណៈ សមស្របចំពោះគោលការណ៍មិនដាក់ទណ្ឌកម្ម។</u>

*សំណួរទី១៩៖ តើឯកឧត្តម លោកជំទាវ លោក លោកស្រី មានឧទាហរណ៍ នៃការប្រតិបត្តិល្អ និងអនុសាសន៍អ្វីខ្លះ ដើម្បីសម្រេចបានគោលការណ៍មិនដាក់ទណ្ឌកម្ម នៅក្នុងច្បាប់ គោលនយោបាយ និងការប្រតិបត្តិ?*

*សំណួរទី២០៖ ជាចុងក្រោយតើ ឯកឧត្តម លោកជំទាវ លោក លោកស្រី មានមតិយោបល់អ្វីបន្ថែម លើគោលការមិនដាក់ទណ្ឌកម្ម ឬអនុសាសន៍អំពីឯកសារ ឬអនុសាសន៍អំពីជំនាញការណាមួយ ដែលយើងគួរគប្បីជួបពិភាក្សាជាមួយ ដែរឬទេ?*

ឆ្លើយតបទៅនឹងសំណួរទី១៩ និងទី២០ លោកជំទាវ ជូ ប៊ុនអេង បានថ្លែងអំណរគុណដល់លោកស្រី ម៉ារីកា ម៉ាក់កាដាំ ដែលបានធ្វើការស្រាវជ្រាវនេះ ហើយសង្ឃឹមថា លទ្ធផលនៃការស្រាវជ្រាវនេះនឹងជួយ បង្កើនការយល់ដឹងដល់បណ្តាប្រទេសក្នុងតំបន់ ក៏ដូចជាក្នុងពិភពលោកថា កម្ពុជាបាននឹងកំពុងខិតខំក្នុងការអនុវត្តតាម គោលការណ៍មិនដាក់ទណ្ឌកម្មលើជនរងគ្រោះ និងតែងតែទទួលយកមកអនុវត្តនូវគ្រប់បទដ្ឋានគតិយុត្តជា អន្តរជាតិ ថ្នាក់តំបន់ ពហុភាគី ត្រីភាគី ទ្វេភាគី ដោយផ្តោតទៅលើការគោរពសិទ្ធិមនុស្ស សិទ្ធិស្ត្រីនិងកុមារ ជាពិសេសសិទ្ធិជនរងគ្រោះ ហើយកម្ពុជាក៏បាននឹងកំពុងខិតខំកែលម្អ នីតិវិធី របៀបរបបការងារក្នុងការសហការ ជាមួយបណ្តាប្រទេសពាក់ព័ន្ធ។ ទន្ទឹមនិងនេះ យើងក៏សូមអំពាវនាវដល់បណ្តាប្រទេសដែលបានទទួលយកនូវពលរដ្ឋខ្មែរ ក៏ដូចជាការប្រើប្រាស់ពលករអន្តោប្រវេសន៍ ជាជនទេសន្តរប្រវេសន៍កម្ពុជា សូមមេត្តាផ្តល់នូវកិច្ចសហការ ឱ្យកាន់តែល្អប្រសើររវាងប្រទេសបញ្ជូន និងប្រទេសទទួល ដើម្បីដោះស្រាយបញ្ហានានា ដែលពាក់ព័ន្ធនឹងជនទេសន្តរប្រវេសន៍របស់យើង ដែលបានចូលទៅ ឬស្នាក់នៅធ្វើការនៅឯប្រទេសទាំងនោះ នៅក្នុងអំឡុងពេលនៃទេសន្តរប្រវេសន៍ និងជួយផ្តល់នូវកិច្ចការពារពេញលេញដល់ជនរងគ្រោះ តាមគោលការណ៍មិនដាក់ទណ្ឌកម្មលើជនរងគ្រោះ ដើម្បីផ្តល់នូវភាពយុត្តិធម៌ដល់ជនរងគ្រោះ។ ក្នុងនាមគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សូមស្នើឱ្យមានកិច្ចសហការឱ្យបានទូលំទូលាយជាងនេះដើម្បីរួមគ្នាការពារដល់ជនរងគ្រោះ ទោះបីជាសញ្ជាតិណាក៏ដោយ ដែលមានវត្តមាននៅក្នុងប្រទេសរៀងៗខ្លួន។ តាងនាមឱ្យរាជរដ្ឋាភិបាលកម្ពុជា នាងខ្ញុំសូមថ្លែងអំណរគុណចំពោះការរៀបចំនូវកិច្ចប្រជុំតុមូលនេះ និងសូមអរគុណចំពោះការផ្តល់ឱកាសក្នុងការបញ្ចេញមតិយោបល់ ដែលយើងគិតថាអាចនឹងមានការផ្តល់បន្ថែមប្រសិនបើមានចំណុច ដែលនៅមិនទាន់ច្បាស់លាស់ និងសង្ឃឹមថាអ្នកស្រាវជ្រាវជាពិសេស លោកស្រី អាម៉ារី ម៉ាក់កាដាំ ក៏ដូចអ្នកដទៃទៀតបានយល់គ្នាកាន់តែច្បាស់។ សូមអរគុណ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង១១និង៥៤នាទី ថ្ងៃខែឆ្នាំដដែល ក្នុងបរិយាកាសសិទ្ធស្នាលបំផុត។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១

**លេខាធិការ**

Ramin

ឧត្តមសេនីយ៍ទោ. **អ៊ុំ ភាមិន្ទ**

គោរពជូន
**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**
មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

ថ្ងៃ...ចន្ទ...១២.កើត.....ខែ..បឋមាសាឍ..ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី...២១... ខែ...មិថុនា...ឆ្នាំ២០២១

**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯក វេជ្ជ.**ប៊ុណ្ណ សំខាន់**